# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ២០២១ ដនស/រ.ស.ល.

ថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៧

**ជម្រាបមក**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត**

**កម្មវត្ថុ** : ការពង្រឹងការត្រួតពិនិត្យការដ្ឋានសំណង់

**យោង** :
- អនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ៤២ អនក្រ/បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- ប្រកាសលេខ ៣២ អនក្រ/បក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសរួមលេខ ១២២៩ ប្រក.មផ.ដនស ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០០៩ រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត

សេចក្តីដូចចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជម្រាបលោកប្រធានមន្ទីរជ្រាបថា ដើម្បីទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត និងការសាងសង់ខុសពីលិខិតអនុញ្ញាត និងប្លង់អនុញ្ញាត ស្នើសុំលោកប្រធានមន្ទីរ ៖

១- ចុះពិនិត្យតាមដានជាប្រចាំការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាក់ទង នឹងការសាងសង់ និងឯកសារបច្ចេកទេសនានានៅគ្រប់ការដ្ឋានសំណង់ទាំងអស់ដែលកំពុងដំណើរការសាងសង់ក្នុងភូមិសាស្ត្ររបស់ខ្លួន ។

២- ក្នុងករណីពិនិត្យឃើញមានកំហុស ត្រូវណែនាំឱ្យម្ចាស់សំណង់ផ្អាកការងារសាងសង់ជាបណ្តោះអាសន្ន ដើម្បីធ្វើការកែតម្រូវ ។

៣- ក្នុងករណីម្ចាស់សំណង់មិនសហការ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវធ្វើលិខិតផ្អាកការដ្ឋានជាផ្លូវការ និងលើកវិធានការដោះស្រាយ ។

៤- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍ប្រចាំសប្តាហ៍មកអគ្គនាយកដ្ឋានសំណង់ ដើម្បីពិនិត្យ តាមដាន និងបូកសរុបរបាយការណ៍ជូនក្រសួង ។

អាស្រ័យហេតុនេះ សូម**លោកប្រធានមន្ទីរ** ចាត់ចែងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។
សូម**លោកប្រធានមន្ទីរ** ទទួលនូវការរាប់អានពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកក្រោមឱវាទក្រសួងដ.ន.ស
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ /ទូរសារ (885) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com